**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សណ្ឋាគារ ញូវ រីវើរ សាយ

**NEW RIVERSIDE HOTEL**

# <u>កិច្ចព្រមព្រៀង</u>

## ស្តីពីការព្យួរកិច្ចសន្យាការងាររវាងតំណាងកម្មករនិយោជិត និង និយោជក

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធនឹងការព្យួរការងារអោយបានសមស្របតាមសេចក្តីណែនាំលេខៈ ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២០ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់ភាគីទាំងពីរបានឯកភាពយល់ព្រមព្យួរកិច្ចសន្យាការងារចំពោះកម្មករ។ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចំនួន ៤៣នាក់ (ស្រី ២០នាក់)ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៤៥នាក់ (ស្រី ២០នាក់) រយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ២០២០។ ដោយទទួលបាននូវប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន៤០ដុល្លាអាមេរិចក្នុងរយៈពេលការព្យួរកិច្ចសន្យាការងារនេះ។ សំរាប់ក្រុមហ៊ុនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថម្ភ បន្ថែមទៅដល់បុគ្គលិក ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនទទួលរងផលប៉ះពាល់ពីជំងឺ កូវីដ-១៩ (Covid-19)បាត់បង់ប្រាក់ចំណូល។

តាមការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ១៥ និង ៣០នាទី នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២០។ ដោយមានចុះហត្ថលេខាព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោមៈ

| | |
|---|---|
| **ភាគីតំណាងឲ្យនិយោជក** | **ភាគីតំណាងឲ្យយោជិត** |
| **ហត្ថលេខា/ស្នាមមេដៃ** | **ហត្ថលេខា/ស្នាមមេដៃ** |
| ញូវ រីវើរ សាយ NEW RIVERSIDE | |
| **លោក មាន សុធី** | **លោកស្រី ភាច សុគៀស** |
| **នាយកក្រុមហ៊ុន** | **ប្រធានផ្នែកធនធានមនុស្ស** |

Add: 1500m the east of Old Market, 7 Makara Road, Chunlong Village, Sala Kamroeuk Commune, Siem Reap City, Siem Reap Province, Kingdom of Cambodia
H/P: 012999952, 012 550055, Oficial Tel: +855 63 765533, Fax: +855 63761511, E-mail: rservation@newriversidehotel.com, Website: www.newriversidehotel.co